**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១៤៤ សសរ**

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតអនុគណៈកម្មាធិការ ទទួលបន្ទុកការគ្រប់គ្រងដណ្ដាប់សុខភាពជាសកលនៅកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២២១ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគាំពារសង្គម
- បានឃើញអនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការបង្កើតគណៈកម្មាធិការប្រតិបត្តិ និងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម
- យោងតាមការស្នើសុំរបស់ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម

## សម្រេច

**ប្រការ១** .-

ត្រូវបានបង្កើតអនុគណៈកម្មាធិការទទួលបន្ទុកការគ្រប់ដណ្ដប់សុខភាពជាសកល នៅកម្ពុជា សរសេរជាអក្សរកាត់ថា "**អ.គ.ស.ស.**" ជាសេនាធិការរបស់គណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| - ឯកឧត្តម **ចន ណារិទ្ធ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការក្រុមប្រឹក្សាជាតិគាំពារសង្គម | ប្រធាន |
| - ឯកឧត្តម **ម៉ឹង ខណ្ឌារ៉ុំ** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| - ឯកឧត្តម **ហ៊ីង រស្មី** | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| - ឯកឧត្តម **ឥត្ថី សម្បូរណ៍** | អគ្គនាយកទីភ្នាក់ងារជាតិបញ្ជាក់ចំណាយ | អនុប្រធាន |
| - ឯកឧត្តម **ហុក គីមចេង** | អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាលនៃក្រសួងសុខាភិបាល | សមាជិក |
| - ឯកឧត្តម **ឈួន សំរីទ្ធិ** | អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - ឯកឧត្តម **ឌិន ទិសាល** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃក្រសួងសុខាភិបាល | សមាជិក |
| - ឯកឧត្តម **ម៉ូ ច័ន្ទគីរូ** | អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា | សមាជិក |
| - ឯកឧត្តម **ស៊ឹម សុធន** | អគ្គនាយកនៃមូលនិធិជាតិជំនួយសង្គម | សមាជិក |
| - ឯកឧត្តម **ឈា ឆវណ្ណា** | នាយកវិទ្យាស្ថានជាតិសុខភាពសាធារណៈ | សមាជិក |
| - ឯកឧត្តម **ឃុន ចាន់ណារិទ្ធ** | អគ្គនាយករងនៃបេឡាជាតិសន្តិសុខសង្គម | សមាជិក |
| - លោក **ស្រី ឌុង** | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - លោក **មាស ខួនឃៀង** | អគ្គនាយករងនៃនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ នៃក្រសួងមុខងារសាធារណៈ | សមាជិក |
| - លោក **ចាតសូ សុត្រ័គ្រ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការទូទៅនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | សមាជិក |
| - លោក **កែវ អ៊ូលី** | ប្រធាននាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៃក្រសួងផែនការ | សមាជិក |
| - លោកស្រី **ឈា ឆដាគា** | ប្រធានមជ្ឈមណ្ឌលលើកកម្ពស់សុខភាព នៃក្រសួងសុខាភិបាល | សមាជិក |
| - លោក **លី យ៉ាសាក់** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ នៃអគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ | សមាជិក |
| - លោកស្រី **សូ ឆវីរត្ន** | អនុប្រធាននាយកដ្ឋានសុខភាពសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក។ |

សមាសភាព អ.គ.ស.ស. អាចត្រូវបានកែសម្រួល ឬបំពេញបន្ថែម តាមការចាំបាច់។

**ប្រការ២ .-**

អ.គ.ស.ស. មានតួនាទី និងភារកិច្ចក្នុងការតម្រង់ទិស សម្របសម្រួល តាមដាន និងត្រួតពិនិត្យលើគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពពាក់ព័ន្ធ ដូចបានកំណត់ក្នុង ផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា ឆ្នាំ២០២៤-២០៣៥ ដូចខាងក្រោម៖

- សម្របសម្រួលការអនុវត្តទិសដៅគោលនយោបាយអាទិភាពជាយុទ្ធសាស្ត្រ និងផែនការសកម្មភាព ក្នុងផែនទីបង្ហាញផ្លូវ
- ពិនិត្យ និងកំណត់ជម្រើសគោលនយោបាយកែទម្រង់ ក្នុងការអនុវត្តទិសដៅគោលនយោបាយអាទិភាពជាយុទ្ធសាស្ត្រ ក្នុងផែនទីបង្ហាញផ្លូវ
- រៀបចំ និងអនុវត្តផែនការកសាងសមត្ថភាពដល់ស្ថាប័ន និងភាគីពាក់ព័ន្ធ ដើម្បីអនុវត្តគោលនយោបាយ និងអន្តរាគមន៍ក្នុងផែនទីបង្ហាញផ្លូវ
- រៀបចំ និងអនុវត្តផែនការអប់រំ ផ្សព្វផ្សាយ និងលើកកម្ពស់ចំណេះដឹងរបស់ប្រជាពលរដ្ឋអំពីការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំលើវឌ្ឍនភាពនៃការអនុវត្តផែនទីបង្ហាញផ្លូវ វាយតម្លៃពាក់កណ្តាលអាណត្តិ វាយតម្លៃវឌ្ឍនភាពនៃការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា និងការអនុវត្តកម្មវិធីជាតិជំនួយសង្គម របបសន្តិសុខសង្គម និងអន្តរាគមន៍ពាក់ព័ន្ធនឹងការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនទីបង្ហាញផ្លូវ ជូនគណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិគាំពារសង្គម និងរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការចាត់តាំងរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម និងគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាជាតិគាំពារសង្គម។

**ប្រការ៣ .-**

អ.គ.ស.ស. អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន អង្គភាព គណៈឱសថការីកម្ពុជា គណៈគ្រូពេទ្យកម្ពុជា គណៈទន្តពេទ្យកម្ពុជា គណៈគិលានុបដ្ឋាកកម្ពុជា គណៈឆ្មបកម្ពុជា ដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និងសង្គមស៊ីវិលពាក់ព័ន្ធ ចូលរួមប្រជុំ ដើម្បីជំរុញការអនុវត្តផែនទីបង្ហាញផ្លូវនេះ តាមការចាំបាច់។

**ប្រការ៤ .-**

អ.គ.ស.ស. មានលេខាធិការដ្ឋានមួយ ចំណុះឱ្យអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គមជាសេនាធិការ។ លេខាធិការដ្ឋាន អ.គ.ស.ស. មានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| ១. ឯកឧត្តម **ឝក្តី សម្បូរណ៍** | ប្រធាន |
| ២. លោកស្រី **លឹម សូហ្វីយ៉ាហ្វារ៉ែត** | អនុប្រធាន |
| ៣. លោក **សំ សំអឿន** | សមាជិក |

| | |
|---|---|
| ៤. លោក **សាយ ស៊ីវុត្ថា** | សមាជិក |
| ៥. លោក **ជា ទណ្ណារ៉ា** | សមាជិក |
| ៦. លោក **ជា ច័ន្ទជាទីត** | សមាជិក។ |

**ប្រការ៥** .-

លេខាធិការដ្ឋាន អ.គ.ស.ស. មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

**ផ្នែកបច្ចេកទេស៖**

- សិក្សា និងស្នើជម្រើសគោលនយោបាយកែទម្រង់ ក្នុងការអនុវត្តទិសដៅគោលនយោបាយអាទិភាពជាយុទ្ធសាស្ត្រដែលមានកំណត់ក្នុងផែនទីបង្ហាញផ្លូវ
- ពិនិត្យ វិភាគ និងផ្តល់យោបល់លើរាល់ការស្នើគោលនយោបាយពាក់ព័ន្ធនឹងការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា
- សម្របសម្រួល ជំរុញការអនុវត្តទិសដៅគោលនយោបាយ និងផែនការសកម្មភាពដែលមានកំណត់ក្នុងផែនទីបង្ហាញផ្លូវ
- សហការអនុវត្តផែនការសកម្មភាពដែលមានកំណត់ក្នុងផែនទីបង្ហាញផ្លូវ
- សិក្សាស្រាវជ្រាវលើប្រធានបទពាក់ព័ន្ធនឹងការគ្របដណ្តប់សុខភាពជាសកល តាមការចាំបាច់

**ផ្នែកតាមដាន និងវាយតម្លៃ៖**

- រៀបចំក្របខណ្ឌតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនទីបង្ហាញផ្លូវ
- អនុវត្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តផែនទីបង្ហាញផ្លូវ និងវាយតម្លៃពាក់កណ្តាលអាណត្តិ
- តាមដានវឌ្ឍនភាពនៃការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា និងការអនុវត្តកម្មវិធីជាតិជំនួយសង្គម របបសន្តិសុខសង្គម និងអន្តរាគមន៍ពាក់ព័ន្ធនឹងការគ្របដណ្តប់សុខភាពជាសកល
- រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនទីបង្ហាញផ្លូវ ជូនគណៈកម្មាធិការប្រតិបត្តិ និងក្រុមប្រឹក្សាជាតិគាំពារសង្គម និងរាជរដ្ឋាភិបាល

**ផ្នែកសម្របសម្រួល៖**

- រៀបចំ និងអនុវត្តផែនការអប់រំ ផ្សព្វផ្សាយ និងលើកកម្ពស់ចំណេះដឹងស្តីពីការគ្របដណ្តប់សុខភាពជាសកល
- សម្របសម្រួលការរៀបចំ និងអនុវត្តផែនការកសាងសមត្ថភាពដល់ស្ថាប័ន និងភាគីពាក់ព័ន្ធដើម្បីអនុវត្តគោលនយោបាយ និងអន្តរាគមន៍ដែលមានកំណត់ក្នុងផែនទីបង្ហាញផ្លូវ
- សម្របសម្រួលជាមួយដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធ រួមទាំងគាំទ្រផ្នែកគតិយុត្ត ក្នុងដំណើរនៃការអនុវត្តផែនទីបង្ហាញផ្លូវ
- រៀបចំផែនការអភិវឌ្ឍន៍លេខាធិការដ្ឋាន ផែនការសកម្មភាព ផែនការថវិកា និងអនុវត្តសកម្មភាពគាំទ្រការប្រព្រឹត្តទៅរបស់ អ.គ.ស.ស. និងលេខាធិការដ្ឋាន
- រៀបចំបូកសរុបរបាយការណ៍ការងារប្រចាំគ្រារបស់លេខាធិការដ្ឋាន។

**ប្រការ៦ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៧ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានក្រុមប្រឹក្សាជាតិគាំពារសង្គម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសមាសភាពក្នុងប្រការ ១ និងប្រការ ៤ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១ រោច ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ